# ព្រះរាជក្រម

នស/រកម/០១០៧/០០៥

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៦ ហើយក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យធម្មនុញ្ញភាព និងបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមរយៈសេចក្តីសម្រេចលេខ ០៩០/០០១/២០០៧ កបធ.ច ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០០៧ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

# ច្បាប់
# ស្តីពី
# វិសោធនកម្មច្បាប់ស្តីពីការរៀបចំ
# និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

**មាត្រាតែមួយ.‒**

មាត្រា ១ មាត្រា ៣ ដល់មាត្រា ៥ មាត្រា ១២ មាត្រា ១៤ដល់មាត្រា ១៨ មាត្រា ២២ មាត្រា ២៤ មាត្រា ២៥ មាត្រា ២៧ មាត្រា ២៩ មាត្រា ៣០ និងមាត្រា ៣៤ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ត្រូវបានកែប្រែដូចខាងក្រោម ៖

**មាត្រា ១ .‒ ថ្មី**

ច្បាប់នេះមានគោលដៅបង្កើត និងកំណត់ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ ពិនិត្យនិងសម្រេចអំពីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

**មាត្រា ៣ .‒ ថ្មី**

សមាជិកទាំង ៩ រូប នៃក្រុមប្រឹក្សាធម្មនុញ្ញត្រូវជ្រើសរើសក្នុងចំណោមឥស្សរជនដែលមានសញ្ជាតិខ្មែរពីកំណើត មានអាយុយ៉ាងតិច ៤៥ឆ្នាំ មានសញ្ញាប័ត្រចាប់ពីឧត្តមសិក្សាឡើងទៅខាងច្បាប់ ខាងរដ្ឋបាល ខាងការទូត ឬ ខាងសេដ្ឋកិច្ច ហើយដែលមានបទពិសោធន៍ក្នុងការងារយ៉ាងតិច ១៥ ឆ្នាំ ។

សមាជិកនៃក្រុមប្រឹក្សាធម្មនុញ្ញ ៣ រូប ត្រូវតែងតាំងដោយព្រះមហាក្សត្រ ៣ រូប ត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ហើយ៣រូប ទៀតត្រូវជ្រើសតាំងដោយរដ្ឋសភាតាមមតិភាគច្រើនដាច់ខាតនៃសមាជិកនៃរដ្ឋសភាទាំងមូល ។

ការជ្រើសតាំងដោយរដ្ឋសភាអាចធ្វើឡើងជាពីរលើកបាន ។

ក្នុងអាណត្តិទី ១ បើការបោះឆ្នោតលើកទី ១ មិនបានទទួលមតិភាគច្រើនដាច់ខាតនោះ ត្រូវបោះឆ្នោតជាលើកទី ២ ដោយយកអ្នកដែលបានទទួលសំឡេងច្រើនជាងគេចំនួនយ៉ាងច្រើន ៥រូប មកបោះឆ្នោតឡើងវិញ ។ ការបោះឆ្នោតលើកទី ២ នេះ ត្រូវយកតាមមតិភាគច្រើនដោយប្រៀប ។ អ្នកដែលទទួលបានសំឡេងច្រើនជាងគេត្រូវតែងតាំងសម្រាប់ ៩ ឆ្នាំ អ្នកដែលទទួលបានសំឡេងបន្ទាប់ត្រូវតែងតាំងសម្រាប់ ៦ឆ្នាំ និងអ្នកដែលទទួលបានសំឡេងបន្ទាប់មកទៀតត្រូវតែងតាំងសម្រាប់ ៣ឆ្នាំ ។

ក្នុងអាណត្តិបន្តបន្ទាប់ បើការបោះឆ្នោតលើកទី ១ មិនបានទទួលមតិភាគច្រើនដាច់ខាតនោះ ត្រូវបោះឆ្នោតជាលើកទី ២ ដោយយកអ្នកដែលបានទទួលសំឡេងច្រើនជាងគេចំនួន ២រូប មកបោះឆ្នោតឡើងវិញ ។ ការបោះឆ្នោតលើកទី ២ នេះ ត្រូវយកតាមមតិភាគច្រើនដោយប្រៀប ។

ក្នុងករណីដែលបេក្ខជនទទួលបានសំឡេងស្មើគ្នានោះ ត្រូវយកអ្នកដែលមានអាយុច្រើនជាងគេ ។

បេក្ខជនម្នាក់ៗដែលនឹងត្រូវជ្រើសតាំងដោយរដ្ឋសភា ត្រូវមានហត្ថលេខាគាំទ្រជាមុនពីសមាជិករដ្ឋសភាចំនួនមួយភាគដប់នៃសមាជិកទាំងមូល ។ សមាជិករដ្ឋសភា ១រូប មានសិទ្ធិគាំទ្របានតែបេក្ខជន ១រូប ប៉ុណ្ណោះ ។

## មាត្រា ៤ .- ថ្មី

ក្នុងរយៈពេលបីឆ្នាំម្តង បីឆ្នាំម្តង សមាជិកចំនួន ៣រូប ត្រូវផ្លាស់ប្តូរនិងតែងតាំងជាថ្មី គឺ ១រូបតែងតាំងដោយព្រះមហាក្សត្រ ១រូបតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និង ១រូបទៀតជ្រើសតាំងដោយរដ្ឋសភា ។

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញត្រូវបានជ្រើសតាំងតាមការបោះឆ្នោតដោយសមាជិកក្រុមប្រឹក្សាធម្មនុញ្ញរៀងរាល់ ៣ឆ្នាំម្តង តាមមតិភាគច្រើនដាច់ខាតនៃសមាជិកទាំងមូល ក្រោយពីសមាជិក ៣រូប ចូលកាន់តំណែង ។

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញចាស់អាចត្រូវជ្រើសតាំងជាថ្មីបាន ។

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ។

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញមានឋានៈ និងបុព្វសិទ្ធិស្មើនឹងប្រធានរដ្ឋសភា ។

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញមានឋានៈ និងបុព្វសិទ្ធិស្មើនឹងអនុប្រធានរដ្ឋសភា ។

អតីតសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ទទួលប្រាក់សោធននិវត្តន៍ប្រចាំខែស្របតាមលក្ខខណ្ឌ និងរូបមន្តសម្រាប់គណនារៀបចំរបបសោធននិវត្តន៍របស់អតីតតំណាងរាស្ត្រ ។

## មាត្រា ៥ .ថ្មី

មុខងារសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មានវិសមិតភាពជាមួយនឹងមុខងារជាសមាជិករាជរដ្ឋាភិបាល សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា ប្រធាន អនុប្រធានគណបក្សនយោបាយ ប្រធាន អនុប្រធានសហជីព និងចៅក្រមក្នុងតំណែង ។

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញមិនត្រូវបំពេញមុខតំណែង និងមុខរបរផ្សេងទៀតនៅក្នុងអាណត្តិរបស់ខ្លួនឡើយ ។

អ្នកដែលបានតែងតាំងជាសមាជិកនៃក្រុមប្រឹក្សាធម្មនុញ្ញ មុនចូលកាន់តំណែង ត្រូវសុំលាឈប់ជាបណ្តោះអាសន្នពីតំណែង ឬ មុខរបរទាំងអស់ដែលបានចែងក្នុងវាក្យខ័ណ្ឌខាងលើ ។

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅសមាជិក ដែលនៅក្នុងមុខតំណែងនិងមុខរបរខាងលើ ឱ្យសុំលាឈប់ពីតំណែង ឬ មុខរបរនោះជាបន្ទាន់ ។

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញត្រូវសុំដកខ្លួនចេញពីរឿងទាំងឡាយណាដែលផលប្រយោជន៍ផ្ទាល់ខ្លួនពាក់ព័ន្ធក្នុងរឿងនោះ ។ ការសុំដកខ្លួនឬការតម្រូវឱ្យដកខ្លួន ត្រូវសម្រេចដោយក្រុមប្រឹក្សាធម្មនុញ្ញ តាមមតិភាគច្រើនដាច់ខាតនៃសមាជិកទាំងមូល ។

## មាត្រា ១២ .ថ្មី

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

បទបញ្ញាផ្ទៃក្នុងត្រូវអនុម័តដោយមតិភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹក្សាធម្ម-នុញ្ញទាំងមូល ។

ក្រុមប្រឹក្សាធម្មនុញ្ញមានអគ្គលេខាធិការដ្ឋានមួយជាជំនួយការ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានត្រូវកំណត់ដោយអនុក្រឹត្យ ។

## មាត្រា ១៤ .– ថ្មី

កិច្ចប្រជុំរបស់ក្រុមប្រឹក្សាធម្មនុញ្ញត្រូវកោះអញ្ជើញដោយប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ឬដោយសមាជិកដែលមានអាយុច្រើនជាងគេ បើប្រធានមានធុរៈមិនអាចធ្វើបាន ។

កិច្ចប្រជុំនៃក្រុមប្រឹក្សាធម្មនុញ្ញអាចចាត់ទុកជាបានការ លុះត្រាតែមានសមាជិកលើសពីពាក់កណ្ដាលចូលរួមប្រជុំ ។

## មាត្រា ១៥ .– ថ្មី

ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋ-ធម្មនុញ្ញ និងច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ ហើយក្នុងក្របខ័ណ្ឌនៃការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ ។

## មាត្រា ១៦ .– ថ្មី

ច្បាប់រៀបចំអង្គការ និងវិសោធនកម្មនៃច្បាប់រៀបចំអង្គការ ក្រោយពីរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ ត្រូវដាក់ជូនក្រុមប្រឹក្សាធម្មនុញ្ញ ដោយប្រធានរដ្ឋសភា ដើម្បីពិនិត្យតើច្បាប់នោះស្រប ឬមិនស្របនឹងរដ្ឋធម្មនុញ្ញមុននឹងត្រូវបានប្រកាសឱ្យប្រើ ។

បទបញ្ញាផ្ទៃក្នុងព្រឹទ្ធសភា និងវិសោធនកម្មបទបញ្ញាផ្ទៃក្នុងព្រឹទ្ធសភា ក្រោយពីព្រឹទ្ធ-សភាអនុម័តរួច ត្រូវដាក់ជូនក្រុមប្រឹក្សាធម្មនុញ្ញ ដោយប្រធានព្រឹទ្ធសភា ដើម្បីពិនិត្យតើបទបញ្ញាផ្ទៃក្នុងនោះស្រប ឬមិនស្របនឹងរដ្ឋធម្មនុញ្ញ មុននឹងត្រូវបានប្រកាសឱ្យប្រើ ។

បទបញ្ញាផ្ទៃក្នុងរដ្ឋសភា និងវិសោធនកម្មបទបញ្ញាផ្ទៃក្នុងរដ្ឋសភា ក្រោយពីរដ្ឋសភាអនុម័តរួច ត្រូវដាក់ជូនក្រុមប្រឹក្សាធម្មនុញ្ញ ដោយប្រធានរដ្ឋសភា ដើម្បីពិនិត្យតើបទបញ្ញាផ្ទៃក្នុងនោះស្រប ឬ មិនស្របនឹងរដ្ឋធម្មនុញ្ញ មុននឹងត្រូវបានប្រកាសឱ្យប្រើ ។

**មាត្រា ១៧ .- ថ្មី**

ព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន ឬសមាជិករដ្ឋសភាចំនួនមួយភាគដប់ អាចបញ្ជូនច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយទៅឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងប្រកាសឱ្យប្រើ ។

**មាត្រា ១៨ .- ថ្មី**

ក្រោយពីច្បាប់ណាមួយត្រូវបានប្រកាសឱ្យប្រើ ព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន សមាជិករដ្ឋសភាចំនួនមួយភាគដប់ ឬតុលាការ អាចសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យអំពីធម្មនុញ្ញភាពនៃច្បាប់នោះ ។

ប្រជារាស្ត្រមានសិទ្ធិប្តឹងអំពីអធម្មនុញ្ញភាពនៃច្បាប់ ឬសុំឱ្យបកស្រាយច្បាប់ទៅក្រុមប្រឹក្សាធម្មនុញ្ញបាន តាមរយៈប្រធានរដ្ឋសភា ឬ តំណាងរាស្ត្រ ឬប្រធានព្រឹទ្ធសភា ឬសមាជិកព្រឹទ្ធសភា ដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើ ។

**មាត្រា ២២ .- ថ្មី**

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចសេចក្តីជាលាយលក្ខណ៍អក្សរលើគ្រប់ករណីដែលត្រូវបានដាក់ជូនក្នុងរយៈពេល ៣០ថ្ងៃ ។ ប្រសិនបើជាការប្រញាប់ រយៈពេលនេះ ត្រូវបន្ថយមកត្រឹម ៨ថ្ងៃ ។

ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យពិចារណាលើធម្មនុញ្ញភាព ឬបកស្រាយច្បាប់ ដោយផ្អែកលើសេចក្តីរាយការណ៍របស់សមាជិកដែលប្រធានបានប្រគល់ភារកិច្ចឱ្យពិនិត្យរាយការណ៍ ។ សមាជិករាយការណ៍ជាសមាជិកនៃក្រុម របស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលមានចែងក្នុងមាត្រា ៣០ថ្មី នៃច្បាប់នេះ ។

ក្រុមប្រឹក្សាធម្មនុញ្ញសម្រេចសេចក្តីតាមមតិភាគច្រើនដាច់ខាតនៃសមាជិកទាំងមូល ។ ក្នុងករណីដែលបែកសំឡេងជាពីរស្មើគ្នា សំឡេងរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញជាសំឡេងឧត្តមានុភាព ។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញត្រូវបញ្ជាក់អំពីហេតុផល ។

**មាត្រា ២៤ .– ថ្មី**

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញត្រូវផ្ញើថ្វាយព្រះមហាក្សត្រ ជូនប្រធានព្រឹទ្ធសភា ជូនប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី និងប្រធានតុលាការកំពូល និងចុះផ្សាយក្នុងរាជកិច្ច ។

ប្រធានព្រឹទ្ធសភាត្រូវជូនដំណឹងអំពីសេចក្តីសម្រេចនេះដល់សមាជិកព្រឹទ្ធសភាទាំងអស់ ។

ប្រធានរដ្ឋសភាត្រូវជូនដំណឹងអំពីសេចក្តីសម្រេចនេះដល់សមាជិករដ្ឋសភាទាំងអស់ ។

នាយករដ្ឋមន្ត្រីត្រូវជូនដំណឹងអំពីសេចក្តីសម្រេចនេះដល់សមាជិករាជរដ្ឋាភិបាលទាំងអស់ ។

ប្រធានតុលាការកំពូលត្រូវជូនដំណឹងអំពីសេចក្តីសម្រេចនេះដល់តុលាការសាមី ។

## ផ្នែកទី ៣
## សមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ចំពោះការបោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោត ជ្រើសតាំងសមាជិកព្រឹទ្ធសភា

**មាត្រា ២៥ .– ថ្មី**

ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិពិនិត្យ និងសម្រេចអំពីវិវាទកម្ម ទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

**មាត្រា ២៧ .– ថ្មី**

ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យនិងសម្រេច :

១-លើបណ្តឹងតវ៉ាដោយផ្ទាល់អំពីលទ្ធផលនៃការបោះឆ្នោត ដែលបុគ្គល ឬគណបក្សនយោបាយដែលបានឈរឈ្មោះបោះឆ្នោតមិនសុខចិត្តនឹងលទ្ធផលនៃការបោះឆ្នោត ។ បណ្តឹងនេះត្រូវធ្វើឡើងក្នុងរយៈពេល ៧២ម៉ោង យ៉ាងយូរ បន្ទាប់ពីការប្រកាសលទ្ធផលបណ្តោះអាសន្ន ។

២-លើបណ្តឹងតវ៉ារបស់បុគ្គល ឬ គណបក្សដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលសម្រេចបដិសេធការតវ៉ាអំពីលទ្ធផលនៃការបោះឆ្នោត ។ ការប្តឹងតវ៉ានេះត្រូវធ្វើឡើងក្នុងរយៈពេល ៧២ ម៉ោង យ៉ាងយូរក្រោយពីបានទទួលលិខិតជូនដំណឹងពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចករណីខាងលើក្នុងរយៈពេល ២០ថ្ងៃយ៉ាងយូរ បន្ទាប់ពីបានទទួលពាក្យបណ្តឹង ។

## មាត្រា ២៩ .- ថ្មី

ពាក្យបណ្តឹងតវ៉ាគ្មានអានុភាពផ្អាកការអនុវត្តទេ ។ ប៉ុន្តែក្នុងពេលរង់ចាំសេចក្តីសម្រេចស្ថាពរក្រុមប្រឹក្សាធម្មនុញ្ញ បើយល់ឃើញថាចាំបាច់ អាចចេញបញ្ជាជាបឋមមួយដើម្បីព្យួរជាបណ្តោះអាសន្ន នូវលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រណាម្នាក់ ឬសមាជិកព្រឹទ្ធសភាណាម្នាក់ ឬគណបក្សនយោបាយណាមួយដែលគេប្តឹងតវ៉ាបាន ។ បញ្ជានេះនឹងត្រូវបញ្ចប់អានុភាពនៅពេលដែលក្រុមប្រឹក្សាធម្មនុញ្ញចេញសេចក្តីសម្រេចជាស្ថាពរ ។

## មាត្រា ៣០ .- ថ្មី

ដើម្បីស្រាវជ្រាវស៊ើបអង្កេតអំពីវិវាទកម្មទាក់ទងទៅនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងជ្រើសតាំងសមាជិកព្រឹទ្ធសភា ក៏ដូចជាការស្រាវជ្រាវត្រួតពិនិត្យធម្មនុញ្ញភាព ឬបកស្រាយច្បាប់ ក្រុមប្រឹក្សាធម្មនុញ្ញចែកចេញជា ៣ក្រុម ។ ក្រុមនីមួយៗមានសមាជិក ៣រូប ដែល ១រូបជាសមាជិកតែងតាំងដោយព្រះមហាក្សត្រ ១រូបជាសមាជិកជ្រើសតាំងដោយរដ្ឋសភា និង ១រូបទៀតជាសមាជិកតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ សមាជិកក្នុងក្រុមទាំង ៣ នេះ ត្រូវជ្រើសរើសដោយវិធីចាប់ឆ្នោត ក្រោមអធិបតីភាពនៃប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ។

មាត្រា ៣៤ .‑ ថ្មី

ក្រុមប្រឹក្សាធម្មនុញ្ញសម្រេចសេចក្តីក្នុងករណីដែលមានការតវ៉ាអំពីនីយតភាពនៃការបោះឆ្នោត អំពីភាពអាចជ្រើសតាំងបាននៃបេក្ខជនសម្រាប់បោះឆ្នោត និងភាពអាចជ្រើសតាំងបាននៃបេក្ខជនដែលប្រកាសថាជាប់ឆ្នោត ។

ក្រុមប្រឹក្សាធម្មនុញ្ញអាចយល់ស្រប ឬមិនយល់ស្របតាមសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាចប្រកាសមោឃភាពនៃការបោះឆ្នោតដែលគេប្តឹងតវ៉ា ឬប្រកាសថាបេក្ខជនជាប់ឆ្នោតដោយត្រឹមត្រូវ ។

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចសេចក្តីតាមមតិភាគច្រើនដាច់ខាតនៃសមាជិកទាំងមូល ។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញត្រូវបញ្ជាក់អំពីហេតុផល ។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញជាសេចក្តីសម្រេចស្ថាពរបិទផ្លូវតវ៉ា ។

សេចក្តីសម្រេចនេះត្រូវថ្វាយព្រះមហាក្សត្រ បញ្ជូនទៅព្រឹទ្ធសភា ឬរដ្ឋសភា និងរាជរដ្ឋាភិបាល ហើយត្រូវចុះក្នុងរាជកិច្ច ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកម.០៧០១.០៤៤

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ: ៦៥ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០០៧

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**យុន ជិនកេន**